# ព្រះរាជក្រម

## យើង

នស/រកម/០១២២/០០៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ០២៥
ថ្ងៃ: ពុធ ទី ២ ខែ កុម្ភៈ ឆ្នាំ២០២២
ម៉ោង: ១១:០០នាទី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
ព្រះរាជវាំង
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ មាត្រា១៦៦ មាត្រា១៧៥ មាត្រា១៨២ មាត្រា១៨៣ មាត្រា១៨៤ មាត្រា១៨៥ មាត្រា១៨៦ មាត្រា១៨៧ មាត្រា១៨៨ មាត្រា១៨៩ មាត្រា១៩០ និងមាត្រា១៩៦
- ដោយកែប្រែ មាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៥៩ មាត្រា៦២ មាត្រា៨៧ មាត្រា១០១ មាត្រា១០៦ មាត្រា១១០ មាត្រា១១៤ មាត្រា១១៥ មាត្រា១៣៧ មាត្រា១៤៤ មាត្រា១៦១ មាត្រា១៧៤ មាត្រា១៩២ មាត្រា១៩៥ មាត្រា២២៥ មាត្រា២៣៤ មាត្រា២៥៥ មាត្រា២៦២ មាត្រា២៧០ និងមាត្រា២៧១ និងដោយកែប្រែជំពូកនិងផ្នែក ព្រមទាំងបន្ថែមមាត្រា៨ ស្ទួន មាត្រា៥៣ ស្ទួន ក្នុងជំពូកទី២ និងមាត្រា១៤៧ ស្ទួន ក្នុងជំពូកទី៣ ដូចតទៅ៖

**មាត្រា១ .- ថ្មី**

ច្បាប់នេះកំណត់ពីទម្រង់នៃសហគ្រាសពាណិជ្ជកម្មដែលជាសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនិងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

**មាត្រា២ .- ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១-បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

**២-ពាណិជ្ជករ** សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបររបស់ខ្លួនជាប្រចាំ។

**៣-មន្ត្រីចុះបញ្ជី** សំដៅដល់អ្នកទទួលចុះបញ្ជីដែលបានតែងតាំងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

**៤-ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម** សំដៅដល់ការិយាល័យដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

**៥-បុត្រសម្ព័ន្ធ** សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនមួយផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ"។

៥.១-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានក្រុមហ៊ុនសហកម្មសិទ្ធិមេកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ។

៥.២-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនត្រូវបានក្រុមហ៊ុនមូលធនមេត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងបុត្រសម្ព័ន្ធនោះ។

**៦-លេខាធិការរបស់ក្រុមហ៊ុន** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួលនិងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា៣ .– ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមូលធន ត្រូវមានលេខាធិការរបស់ក្រុមហ៊ុនដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដនិងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា។

ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់លេខាធិការរបស់ក្រុមហ៊ុន ហើយលេខាធិការរបស់ក្រុមហ៊ុននោះត្រូវតែជារូបវន្តបុគ្គលដែលមានកាយសម្បទានិងសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។ លេខាធិការរបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតផ្លូវការនិងឯកសារទាំងឡាយព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការ ក្នុងនាមក្រុមហ៊ុនមូលធននោះ។

សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីនិងការផ្លាស់ប្តូរលេខាធិការរបស់ក្រុមហ៊ុនក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។

សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .– ថ្មី**

ឯកសារនិងព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនមូលធនត្រូវប្រគល់ទៅឱ្យលេខាធិការរបស់ក្រុមហ៊ុននៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។

ឯកសារនិងព័ត៌មានត្រូវប្រគល់ទៅឱ្យម្ចាស់សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិក្នុងអំឡុងម៉ោងធ្វើការធម្មតា លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករទូទៅបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះត្រូវផ្ញើទៅឱ្យក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្ម។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីតាមគ្រប់មធ្យោបាយ ត្រូវបានចាត់ទុកថាជាការបញ្ជូនទៅសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធននោះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៥ .– ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំស្មើនឹងពីរដងធំជាងភាសាដទៃទៀត ប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរនិងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរនៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន។

## ជំពូកទី២ ថ្មី

## សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិ

### ផ្នែកទី១ ថ្មី

### សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ក (ថ្មី). ការបង្កើតសហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

**មាត្រា៨ .– ស្ទួន**

សហគ្រាសឯកបុគ្គល គឺជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។

ម្ចាស់សហគ្រាសឯកបុគ្គល គឺជាពាណិជ្ជករ។

សហគ្រាសឯកបុគ្គល ដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

នាមករណ៍របស់សហគ្រាសឯកបុគ្គលត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល" ឬសរសេរជាអក្សរកាត់ដាក់ខាងចុងឬខាងក្រោម។

កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់សហគ្រាសឯកបុគ្គល គឺជាការទទួលខុសត្រូវដោយផ្ទាល់និងដោយគ្មានកម្រិតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនោះ។ សហគ្រាសឯកបុគ្គលមិនតម្រូវឱ្យមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។ សហគ្រាសឯកបុគ្គលមិនមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីម្ចាស់សហគ្រាសឡើយ។

## ខ (ថ្មី). ការរំលាយ និងការជម្រះបញ្ជីសហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### មាត្រា៥៣ ._ ស្ទួន

ម្ចាស់សហគ្រាសឯកបុគ្គល អាចរំលាយសហគ្រាសរបស់ខ្លួនបាននៅពេលណាក៏បាន។

សហគ្រាសឯកបុគ្គល អាចត្រូវបានរំលាយដោយមូលហេតុដូចខាងក្រោមៈ

- តាមការស្ម័គ្រចិត្ត
- មរណភាពរបស់ម្ចាស់សហគ្រាស
- សេចក្តីសម្រេចរបស់តុលាការ។

នីតិវិធីក្នុងការរំលាយសហគ្រាសឯកបុគ្គលតាមការស្ម័គ្រចិត្តឬមរណភាពរបស់ម្ចាស់សហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានអនុលោមភាពតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា៥៩ ._ ថ្មី

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទដែលបានកំណត់និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ពឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

### មាត្រា៦២ ._ ថ្មី

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរំលាយ រហូតដល់រយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ពីពេលដែលជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះ តម្រូវឱ្យទុកជាភស្តុតាង។

### មាត្រា៨៧ ._ ថ្មី

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## មាត្រា១០១ .- ថ្មី

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ញាតិខ្មែរលុះត្រាតែ៖

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្មនិងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម។

## មាត្រា១០៦ .- ថ្មី

ក្រុមហ៊ុនឬបុគ្គលម្នាក់ដែលជានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោម ជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជន ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបានឡើយ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ឬបានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួនឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ៖

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ។

គ-ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំងឬមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនិងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬលេខាធិការរបស់ក្រុមហ៊ុនណាម្នាក់មិនមានសុពលភាពឬមិនយកជាការបានឡើយ។

ច-ប្រាក់ខ្ចីនិងការធានា ឬការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ។

## មាត្រា១១០ .- ថ្មី

ម្ចាស់ភាគហ៊ុននិងម្ចាស់បំណុលរបស់ក្រុមហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចពិនិត្យគ្រប់ឯកសារដូចដែលបានចែងនៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើកំណត់ចំណាំដោយមិនគិតកម្រៃ។

ប្រសិនបើក្រុមហ៊ុនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាចពិនិត្យមើលគ្រប់ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប។

**មាត្រា១១៤ ._ ថ្មី**

ក្រុមហ៊ុននិងលេខាធិការរបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ។

**មាត្រា១១៥ ._ ថ្មី**

លិខិតស្នាមឬកិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់ ឬលេខាធិការរបស់ក្រុមហ៊ុនម្នាក់ មានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ។

**មាត្រា១៣៧ ._ ថ្មី**

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្ដីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជាៈ

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចីឬកាតព្វកិច្ចទាំងឡាយដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុនឬដល់សាខាមួយរបស់ក្រុមហ៊ុន។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនឬសាខាណាមួយរបស់ក្រុមហ៊ុន។

គ-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាតឬជាការធានា។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ។

**មាត្រា១៤៤ ._ ថ្មី**

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នានិងរួមបញ្ចូលនូវសិទ្ធិៈ

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

២-ក្នុងការទទួលនូវរាល់ភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន។

៣-ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុននៅពេលមានការរំលាយ។

**មាត្រា១៤៧ ._ ស្ទួន**

ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនមូលធនដែលមិនមានបំណងបង្ហាញអត្តសញ្ញាណនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អាចតែងតាំងអ្នកតំណាងឱ្យឈរឈ្មោះជំនួសបាន។ ការតែងតាំងអ្នកតំណាង ត្រូវធ្វើឡើងតាមរយៈកិច្ចសន្យារវាងម្ចាស់ភាគហ៊ុននិងអ្នកតំណាង ដែលជារូបវន្តបុគ្គលឬនីតិបុគ្គល ហៅថាកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន។

ព័ត៌មានពីអត្តសញ្ញាណរបស់ម្ចាស់ភាគហ៊ុននិងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវតម្កល់ទុកនៅក្នុង[illegible]ពាណិជ្ជកម្ម។ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការតម្កល់ព័ត៌មាននិងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៦១ .– ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងផ្នែកទី២នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១-អ្នកទិញដោយសុទ្ធចិត្ត** សំដៅដល់អ្នកទិញដែលបង់ថ្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានបណ្តឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានបោះចេញឱ្យ។

**២-អ្នកជើងសា** សំដៅដល់បុគ្គលជាប់កាតព្វកិច្ចទាំងស្រុងឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជួញដូរមូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ។

៣-*ការប្រគល់* សំដៅដល់ការផ្ទេរការកាន់កាប់ដោយឆន្ទៈ។

៤-*សុទ្ធ* សំដៅដល់ពិតប្រាកដមិនក្លែងក្លាយឬក្លែងបន្លំ។

៥-*ម្ចាស់មូលបត្រ* សំដៅដល់បុគ្គលដែលកាន់កាប់មូលបត្រភាគហ៊ុនក្នុងលក្ខន្តិកៈក្រុមហ៊ុន ដែលត្រូវបានចេញដោយក្រុមហ៊ុនមូលធន។

៦-ចេញបន្ថែម សំដៅដល់ការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្តល់សិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ។

៧-*អ្នកជាវ* សំដៅដល់បុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់ បញ្ចាំ ធ្វើហ៊ីប៉ូតែក ចេញប័ណ្ណ ចេញប័ណ្ណសាជាថ្មី ធ្វើអំណោយនូវមូលបត្រនោះ ឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ។

៨- មូលបត្រ សំដៅដល់លិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល៖

ក-ស្ថិតក្នុងទ្រង់ទ្រាយចុះបញ្ជី។

ខ-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬលើទីផ្សារមូលបត្រ ឬបានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញឬត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ។

គ-ជាប្រភេទមួយឬស៊េរីមួយនៃមូលបត្រ ដែលចែកនៅក្នុងប្រភេទឬស៊េរីនៃលិខិតស្នាម។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗ ក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន។

៩-*ការផ្ទេរ* សំដៅដល់ជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់។

**១០-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា** សំដៅដល់មនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផង។

**មាត្រា១៧៤ .– ថ្មី**

នៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ៖

១-[illegible]ការចុះហត្ថលេខាលើមូលបត្រ ក្នុងករណីចាំបាច់គឺត្រូវបានទទួលស្គាល់ លើកលែងតែ[illegible]ជាក់លាក់។

[illegible]ហត្ថលេខា[illegible]នៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវនិងមានការអនុញ្ញាត។ ប៉ុន្តែប្រសិនបើ[illegible]នៃ[illegible]លេខាត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុតាងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវឬត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចម្លើយបង្ហាញភស្តុតាងផ្ទុយឬកង្វះខាតលើសុពលភាពនៃមូលបត្រនោះ។

ឃ-បើភាគីចុងចម្លើយលើកឡើងនូវភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនោះទៅវិញ។

**មាត្រា១៩២ ._ ថ្មី**

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវពីបុគ្គលណាមួយក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុទ្ធចិត្តដើម្បី៖

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ឬមួយផ្នែក។

៣-ទាមទាររាល់ការខូចខាតទាំងឡាយ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្តឹងតវ៉ា។

**មាត្រា១៩៥ ._ ថ្មី**

ពេលណាដែលមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ៖

១-ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានអនុវត្ត។

២-ការផ្ទេរកម្មសិទ្ធិនោះគឺស្របតាមច្បាប់ឬផ្ទេរទៅឱ្យអ្នកជាពិតប្រាកដ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជី ការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខាន ឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ។

**មាត្រា២២៥ ._ ថ្មី**

ម្ចាស់ភាគហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយមិនគិតថ្លៃ។

**មាត្រា២៣៤ ._ ថ្មី**

សវនករត្រូវធ្វើការត្រួតពិនិត្យលើចំណុចដែលខ្លួនយល់ថាចាំបាច់ ដើម្បីរាយការណ៍ជូនម្ចាស់ភាគហ៊ុនទាំងឡាយលើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុនឬអភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មាន ការបកស្រាយបំភ្លឺ និងបញ្ជី

គណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ។

សវនកររបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករ ដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន។

ប្រសិនបើអភិបាលឬម្ចាស់ភាគហ៊ុន ទោះបីជាម្ចាស់ភាគហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្នឬសវនករពីមុនក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃមុនមហាសន្និបាត សវនករបច្ចុប្បន្នឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ។

**មាត្រា២៥៥ ._ ថ្មី**

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវ៖

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀតដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី
- តែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។ អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយនិងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទាំងកម្មសិទ្ធិជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនដែលបានរំលាយ រយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំចាប់ពីកាលបរិច្ឆេទជម្រះបញ្ជីរួច។

**មាត្រា២៦២ ._ ថ្មី**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិតដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ។

ក្នុងករណីចាំបាច់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឱ្យក្រុមហ៊ុនធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានដែលបានចុះបញ្ជីឬដែលបានធ្វើប្រតិវេទន៍ប្រចាំឆ្នាំនៅគ្រប់កាលៈទេសៈ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុនមានសិទ្ធិចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារដែលបានធ្វើបច្ចុប្បន្នកម្មដល់ទីស្នាក់ការរបស់ក្រុមហ៊ុន និងតម្រូវឱ្យក្រុមហ៊ុនផ្តល់ព័ត៌មានឬឯកសារបន្ថែម ដើម្បីធានាភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារ។

នីតិវិធីនៃការតម្រូវឱ្យក្រុមហ៊ុនធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានដែលបានចុះបញ្ជីឬធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងការចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤ ថ្មី
## សាខាក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនពាណិជ្ជកម្មបរទេស

**មាត្រា២៧០ .- ថ្មី**

ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលបានបង្កើតឡើងក្រោមច្បាប់នេះ អាចបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកមួយឬច្រើនបាន។ ក្រុមហ៊ុនដែលបង្កើតសាខា ត្រូវហៅថា "ក្រុមហ៊ុនដើម"។

សាខាក្រុមហ៊ុនក្នុងស្រុកគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

សាខាក្រុមហ៊ុនក្នុងស្រុកអាចធ្វើត្រឹមតែសកម្មភាពដែលមានចែងក្នុងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនដើមតែប៉ុណ្ណោះ។

ទ្រព្យសកម្មរបស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើសកម្មភាពនិងកាតព្វកិច្ចរបស់សាខាក្រុមហ៊ុនក្នុងស្រុក។

សាខាក្រុមហ៊ុនក្នុងស្រុកត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូបឬច្រើនរូប ដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម។

នាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជានាមករណ៍របស់ក្រុមហ៊ុនដើម។ នៅពីលើឬនៅពីមុខនាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកនោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុនក្នុងស្រុក"។

សាខាក្រុមហ៊ុនក្នុងស្រុកអាចត្រូវរំលាយបានដោយសេចក្ដីសម្រេចរបស់ក្រុមហ៊ុនដើម ហើយក្រុមហ៊ុនដើមត្រូវស្នើសុំមកក្រសួងពាណិជ្ជកម្មដើម្បីលុបចេញពីបញ្ជីពាណិជ្ជកម្ម។

**មាត្រា២៧១ .- ថ្មី**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមានទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានតាមបែបបទផ្សេងៗ ដូចតទៅ៖

ក-ការិយាល័យតំណាងពាណិជ្ជកម្មឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។

ខ-សាខាក្រុមហ៊ុនពាណិជ្ជកម្ម។

គ-បុត្រសម្ព័ន្ធ។

ការិយាល័យតំណាងពាណិជ្ជកម្មនិងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

**មាត្រា២៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ១៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២២

នរក.២២០១.០៤៧

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**